វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

## ឯកសារស្រាវជ្រាវសង្ខេប

### គណៈកម្មការទី៥ នៃព្រឹទ្ធសភា

# ក្របខ័ណ្ឌច្បាប់ ស្តីពី ការធ្វើអន្តោប្រវេសន៍ នៅកម្ពុជា និងវៀតណាម

ខែវិច្ឆិកា ឆ្នាំ២០១៧

អ្នកស្រាវជ្រាវ៖ **កញ្ញា ហេង នីដា**
**លោក ផ្លូរិនថ៍ ស្មៀរស៍**
**លោក មូសារ អ៊ីស្សាម**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈ ការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក សមាជិកានិងគណៈកម្មការជំនាញរបស់រដ្ឋសភាព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា

១. សេចក្តីផ្តើម ........ 1
២. ក្របខ័ណ្ឌច្បាប់អន្តរជាតិ ........ 1
៣. ទិដ្ឋាការ និងច្បាប់ស្នាក់នៅ ........ 3
៤. ច្បាប់ស្តីពីការងារ ........ 5
៥. ការទទួលបានសញ្ជាតិ ........ 7
ឯកសារយោង ........ 11

## ១. សេចក្តីផ្តើម

ការធ្វើសមាហរណកម្មនៃសហគមន៍អាស៊ាន មានការផ្លាស់ប្តូរកម្លាំងពលកម្មដោយសេរី ដែលមានសារៈសំខាន់សម្រាប់ប្រទេសជាសមាជិកអាស៊ាន ដើម្បីឱ្យមានច្បាប់សមស្រប សម្រាប់គ្រប់គ្រងលើការធ្វើអន្តោប្រវេសន៍ ទាំងផ្នែកពាណិជ្ជកម្ម និងកំលាំងពលកម្ម។ ការធ្វើឲ្យស្របគ្នារវាងច្បាប់អន្តោប្រវេសន៍ក្នុងតំបន់ នឹងជួយទប់ស្កាត់បញ្ហានានាពាក់ព័ន្ធទាំងការធ្វើចំណាកស្រុកក្នុងតំបន់ (រវាងសមាជិកអាស៊ាន) និងក្រៅតំបន់អាស៊ាន។

នៅក្នុងគោលបំណង ផ្តល់នូវទិដ្ឋភាពមួយដែលងាយយល់ ហើយដោយឆ្លើយតបទៅនឹងតម្រូវការរបស់គណៈកម្មការ ឯកសារស្រាវជ្រាវសង្ខេបនេះ នឹងផ្តល់ជូននូវទិដ្ឋភាពទូទៅ ដោយផ្តោតលើតារាងសិក្សា ប្រៀបធៀបក្របខ័ណ្ឌច្បាប់នៅក្នុងប្រទេសកម្ពុជា និងវៀតណាមជៀសជាង ការអធិប្បាយជាលាយល័ក្ខអក្សរ។
ជាពិសេស តារាងសិក្សាប្រៀបធៀបទាំងនេះនឹងផ្តល់នូវទិន្នន័យមួយចំនួនសម្រាប់ឆ្លើយតបទៅនឹងសំណួរសិក្សាចំនួនពីរ ដែលគណៈកម្មការបានលើកឡើង៖
១.តើមានភាពខុសគ្នាសំខាន់ៗអ្វីខ្លះរវាងប្រទេសកម្ពុជា និងវៀតណាម ទាក់ទងនឹងច្បាប់ ស្តីពីអន្តោប្រវេសន៍ និងការចូលសញ្ជាតិ?
២.តើអ្វីខ្លះជាតម្រូវការផ្លូវច្បាប់សម្រាប់ជនអន្តោប្រវេសន៍ពាណិជ្ជកម្ម និងពលករ ដែល មកធ្វើការនៅប្រទេសវៀតណាម ហើយតម្រូវការផ្លូវច្បាប់នោះបានអនុវត្តដោយរបៀបណា?
សំណួរទាំងពីរនេះ នឹងឆ្លើយតបនៅខាងក្រោម ដោយចែកជាបួនផ្នែកសំខាន់ៗ៖ ផ្នែកទី១ ស្តីពីក្របខ័ណ្ឌច្បាប់អន្តរជាតិ ផ្នែកទី២ ច្បាប់ស្តីពី ទិដ្ឋាការចូល និងការស្នាក់នៅ ផ្នែកទី៣ ស្តីពីច្បាប់ការងារ (ពាក់ព័ន្ធទៅនឹងចំណាកស្រុក) និងផ្នែកចុងក្រោយស្តីពី ការចូលសញ្ជាតិ។

## ២. ក្របខ័ណ្ឌច្បាប់អន្តរជាតិ

ប្រទេសវៀតណាម និងកម្ពុជា គឺជាសមាជិកអាស៊ាន នឹងជារដ្ឋហត្ថលេខីនៃសេចក្តីប្រកាសអាស៊ាន។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិដែលមានចំនួនសរុប៨ ខណៈដែលវៀតណាមបានផ្តល់សច្ចាប័នលើអនុសញ្ញាចំនួនប្រាំ។ ប្រទេសទាំងពីរបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងការរើសអើង ប៉ុន្តែកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែម និងអនុសញ្ញាស្តីពី កាការពារជនអន្តោប្រវេសន៍។

| | វៀតណាម | កម្ពុជា |
|---|---|---|
| សហគមន៍សេដ្ឋកិច្ចអាស៊ាន | សមាជិក | សមាជិក |
| សេចក្ដីប្រកាសអាស៊ាន ស្ដីពី ការការពារ និងលើកកម្ពស់សិទ្ធិរបស់ពលករអន្តោប្រវេសន៍ឆ្នាំ២០០៧ | បានចុះហត្ថលេខា | បានចុះហត្ថលេខា |
| សេចក្ដីប្រកាសអាស៊ាន ស្ដីពី ការពង្រឹងការគាំពារសង្គមឆ្នាំ២០១៣ | បានចុះហត្ថលេខា | បានចុះហត្ថលេខា |
| **អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ៖** | | |
| ១. អនុសញ្ញា ស្ដីពី សេរីភាពនៃសមាគម និងការពារសិទ្ធិក្នុងការបង្កើតសមាគម ឆ្នាំ១៩៤៨ (លេខ ៨៧) | X | បានផ្ដល់សច្ចាប័ន |
| ២. អនុសញ្ញា ស្ដីពី សិទ្ធិក្នុងការបង្កើត និងចរចារជាសមូហភាពឆ្នាំ១៩៤៩ (លេខ ៩៨) | X | បានផ្ដល់សច្ចាប័ន |
| ៣. អនុសញ្ញា ស្ដីពី ការងារដោយបង្ខំឆ្នាំ១៩៣០ (លេខ ២៩) | បានផ្ដល់សច្ចាប័ន | បានផ្ដល់សច្ចាប័ន |
| ៤. អនុសញ្ញា ស្ដីពី ការលុបបំបាត់រាល់ទម្រង់ពលកម្មដោយបង្ខំឆ្នាំ១៩៥៧ (លេខ ១០៥) | X | បានផ្ដល់សច្ចាប័ន |
| ៥. អនុសញ្ញា ស្ដីពី អាយុអប្បបរមាឆ្នាំ១៩៧៣ (លេខ ១៣៨) | បានផ្ដល់សច្ចាប័ន | បានផ្ដល់សច្ចាប័ន |
| ៦. អនុសញ្ញា ស្ដីពី ទម្រង់ពលកម្មធ្ងន់ធរលើកុមារឆ្នាំ១៩៩៩ (លេខ ១៨២) | បានផ្ដល់សច្ចាប័ន | បានផ្ដល់សច្ចាប័ន |
| ៧. អនុសញ្ញា ស្ដីពី ការទទួលបានប្រាក់បៀវត្សស្មើគ្នា ឆ្នាំ១៩៥១ (លេខ ១០០) | បានផ្ដល់សច្ចាប័ន | បានផ្ដល់សច្ចាប័ន |
| ៨. អនុសញ្ញា ស្ដីពី ការរើសអើង (ការងារ និងមុខរបរ) ឆ្នាំ១៩៥៨ (លេខ ១១១) | បានផ្ដល់សច្ចាប័ន | បានផ្ដល់សច្ចាប័ន |
| អនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាតិ ស្ដីពី ការការពារសិទ្ធិរបស់ពលករអន្តោប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ(១៩៩០) | X | បានផ្ដល់សច្ចាប័ន |
| អនុសញ្ញាអន្តរជាតិស្ដីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) ១៩៦៦ | បានផ្ដល់សច្ចាប័ន | បានផ្ដល់សច្ចាប័ន |
| អនុសញ្ញា ស្ដីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ឆ្នាំ១៩៧៩ | បានផ្ដល់សច្ចាប័ន | បានផ្ដល់សច្ចាប័ន |
| ពិធីសារបន្ថែមលើអនុសញ្ញា CEDAW ១៩៩៩ | X | បានផ្ដល់សច្ចាប័ន |

## ៣. ទិដ្ឋាការ និងច្បាប់ស្នាក់នៅ

ប្រទេសវៀតណាមមានប្រភេទទិដ្ឋាការច្រើនជាងកម្ពុជា ដោយសារតែប្រទេសវៀតណាមបានបែងចែកប្រភេទទិដ្ឋាការជាក្រុមដោយលម្អិត (ឧទាហរណ៍៖ ទិដ្ឋាការការទូតមានចំនួនបួនប្រភេទខុសៗគ្នា ទៅតាមឋានានុក្រមរបស់គណៈប្រតិភូការទូត)។ វៀតណាមទាមទារការអញ្ជើញជាផ្លូវការ សម្រាប់ប្រភេទទិដ្ឋាការភាគច្រើន។ ខណៈឯប្រទេសកម្ពុជា មិនតម្រូវឱ្យមានការអញ្ជើញនោះទេ ប៉ុន្តែជនបរទេសត្រូវផ្ដល់ឯកសារការងារ ដើម្បីទទួលបានទិដ្ឋាការធម្មតា។ ភាពខុសគ្នាមួយទៀតរវាងប្រទេសទាំងពីរ គឺប្រទេសវៀតណាម "ការអនុញ្ញាតឲ្យស្នាក់នៅ" អនុញ្ញាតឲ្យជនបរទេសស្នាក់នៅដោយគ្មានទិដ្ឋាការ។

| | ប្រទេសវៀតណាម | ប្រទេសកម្ពុជា |
| --- | --- | --- |
| **ប្រភេទទិដ្ឋាការ** | ប្រទេសវៀតណាមមានទិដ្ឋាការចំនួន ២០ប្រភេទផ្សេងៗពីគ្នា[1, មាត្រា៨]<br>• NG1 សម្រាប់គណៈប្រតិភូដែលបានអញ្ជើញដោយអគ្គលេខាធិការនៃគណៈបក្សកុម្មុយនីស្ត ប្រធានាធិបតី ប្រធានរដ្ឋសភា ឬនាយករដ្ឋមន្ត្រី<br>• NG2 សម្រាប់គណៈប្រតិភូដែលបានអញ្ជើញដោយមន្ត្រីរដ្ឋផ្សេងដែលមានឋានៈទាបជាងតាមឋានានុក្រម<br>• NG3 សម្រាប់សមាជិកបេសកកម្មការទូត តំណាងឲ្យផ្នែកនានានៃអង្គការសហប្រជាជាតិ<br>• NG4 សម្រាប់បុគ្គលិកនៃបេសកកម្មការទូត បុគ្គលិកអង្គការសហប្រជាជាតិ<br>• LV1 សម្រាប់បុគ្គលដែលមកធ្វើការជាមួយគណៈបក្សកុម្មុយនីស្ត ឬផ្នែកនានារបស់គណៈបក្ស | ប្រទេសកម្ពុជា មានទិដ្ឋាការចំនួន៦ប្រភេទផ្សេងៗពីគ្នា [2, មាត្រា ៩-១៤]<br>• ប្រភេទ "ការទូត" (A) សម្រាប់អ្នកដែលកាន់លិខិតឆ្លងដែនទូត (diplomatic passport)<br>• ប្រភេទ "ផ្លូវការ" (B) សម្រាប់បុគ្គលិករបស់អង្គការដែលមានអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>• ប្រភេទ "បោរីភាព""Courtesy" (C) ផ្ដល់ដោយក្រសួងពាក់ព័ន្ធ<br>• ប្រភេទ "ឆ្លងកាត់" (D) សម្រាប់បុគ្គលិកកប៉ាល់ យន្តហោះ ឬរថភ្លើងដែលកំពុងធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា<br>• ប្រភេទ "ធម្មតា" (E) សម្រាប់អ្នកធ្វើទស្សនកិច្ច "business" ដែលចែកជា ៦ប្រភេទ៖ |

| | | |
|---|---|---|
| | • LV2 សម្រាប់បុគ្គលដែលមកធ្វើការជាមួយអង្គការដែលជួយកិច្ចការសង្គម ឬសភាពាណិជ្ជកម្មវៀតណាម<br>• ĐT សម្រាប់អ្នកវិនិយោគបរទេស និងមេធាវីបរទេស<br>• DN សម្រាប់និយោជិក ឬកម្មកររបស់ក្រុមហ៊ុននៅប្រទេសវៀតណាម<br>• NN1 សម្រាប់អ្នកគ្រប់គ្រង ឬអ្នកតំណាង នៃអង្គការមិនមែនរដ្ឋា-ភិបាល<br>• NN2 សម្រាប់ប្រធានការិយាល័យតំណាងឲ្យស្ថាប័នបរទេស<br>• NN3 សម្រាប់បុគ្គលមកធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល<br>• DH សម្រាប់និស្សិត ឬអ្នកចុះកម្មសិក្សា<br>• HN សម្រាប់បុគ្គលដែលមកចូលរួមសិក្ខាសាលា<br>• PV1 សម្រាប់អ្នកសារព័ត៌មាន ដែលមានលំនៅអចិន្ត្រៃយ៍នៅប្រទេសវៀតណាម<br>• PV2 សម្រាប់អ្នកសារព័ត៌មាន ដែលមកស្នាក់នៅប្រទេសវៀតណាមក្នុងរយៈពេលខ្លី<br>• LĐ សម្រាប់បុគ្គលដែលមកធ្វើការ<br>• DL សម្រាប់ភ្ញៀវទេសចរណ៍<br>• TT សម្រាប់គ្រួសាររបស់អ្នកដែលប្រើប្រាស់ទិដ្ឋាការប្រភេទ LV1, LV2, ĐT, NN1, NN2, PV1 ឬ ប្រភេទLĐ សម្រាប់គ្រួសាររបស់ប្រជាជនវៀតណាម<br>• VR សម្រាប់បុគ្គលដែលមកសួរសុខទុក្ខសាច់ញាតិ | ○ Eb សម្រាប់និយោជិក ឬកម្មកររបស់ក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា<br>○ Eg<br>○ Ep សម្រាប់បុគ្គលដែលស្វែងរកឱកាសដែលទាក់ទងនឹងមុខរបររបស់ខ្លួន (business opportunities)<br>○ Er សម្រាប់និវត្តន៍ជន<br>○ Es សម្រាប់និស្សិត<br>○ Et សម្រាប់អ្នកជំនាញបច្ចេកទេស<br>• ប្រភេទ "ACMECs" (KHM) សម្រាប់ភ្ញៀវទេសចរណ៍ដែលទស្សនកិច្ចក្នុងតំបន់សហប្រតិបត្តិការសេដ្ឋកិច្ច ឈ្មោះថា "Ayetawady-Chao Phraya-Mekong"<br>• ប្រភេទ "ពិសេស" (K) សម្រាប់អ្នកដែលមានកំណើតជាខ្មែរ<br>• ប្រភេទ "ទេសចរណ៍" (T) |

| | | |
|---|---|---|
| | • SQ សម្រាប់ស្ទង់មើលទីផ្សារ ឬព្យាបាលជំងឺ | |
| **តម្រូវការ** | ប្រទេសវៀតណាម តម្រូវអោយមានការទទួលខុសត្រូវ ឬការអញ្ជើញពីស្ថាប័ន អង្គការ ឬក្រុមហ៊ុនវៀតណាមណាមួយ លើកលែងការទស្សនកិច្ចទេសចរណ៍រយៈពេលខ្លី ការពិនិត្យសុខភាព ឬការសួរសុខទុក្ខក្រុមគ្រួសារ [1, មាត្រា១០-១៤] | បើទោះជាអ្នកដែលមានប្រភេទទិដ្ឋាការប្រភេទ "ធម្មតា" (E) ដូចបានរៀបរាប់ខាងលើ ក៏ត្រូវមានឯកសារពាក់ព័ន្ធដែលបញ្ជាក់ពីស្ថានភាពខ្លួន [2] |
| **ការអនុញ្ញាតិឲ្យស្នាក់នៅ** | អ្នកកាន់លិខិតអនុញ្ញាតឲ្យស្នាក់នៅអាចចូល ឬចាកចេញពីប្រទេសវៀតណាម ដោយគ្មានទិដ្ឋាការ។ ប្រទេសវៀតណាមមានប្រភេទ "លិខិតអនុញ្ញាតឲ្យស្នាក់នៅបណ្តោះអាសន្ន" ខុសៗគ្នា សម្រាប់វិនិយោគិន និស្សិត និងមេធាវី (មានសុពលភាព៥ឆ្នាំ) សម្រាប់តំណាងអង្គការបរទេស (មានសុពលភាព៣ឆ្នាំ) ឬសម្រាប់និយោជិតបរទេស (មានសុពលភាព២ឆ្នាំ) ក៏មានលិខិតអនុញ្ញាតឲ្យស្នាក់នៅ **"ជាអចិន្ត្រៃយ៍"** (មានសុពលភាពរយៈពេល១០ឆ្នាំ) សម្រាប់អ្នកជំនាញការ ជនបរទេសដែលមានគ្រួសារវៀតណាម ជនដែលគ្មានសញ្ជាតិដែលបានរស់នៅក្នុងប្រទេសវៀតណាមមុនឆ្នាំ ២០០០ និងអ្នកដែលបានរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសវៀតណាម [1, មាត្រា៣៩] | ប្រទេសកម្ពុជាមិនមានលិខិតអនុញ្ញាតឲ្យស្នាក់នៅទេ។ ជនបរទេស ដែលស្នាក់នៅរយៈពេលវែង ត្រូវតែពន្យារទិដ្ឋាការ ឲ្យសមស្របចំពោះរយៈពេលដែលពួកគេស្នាក់នៅ។ |

## ៤. ច្បាប់ស្តីពីការងារ

ច្បាប់ស្តីពីការងារ នៅក្នុងប្រទេសទាំងពីរមានលក្ខណៈស្រដៀងគ្នា ចំពោះតម្រូវការពលករបរទេស និងក្រុមហ៊ុនដែលជួលពលករ។ ភាពខុសគ្នាសំខាន់មួយគឺប្រទេសកម្ពុជា មានកំណត់ចំនួនអតិបរមានៃជនបរទេសដែលក្រុមហ៊ុនអាចជួល (លើសពី១០%ត្រូវសុំការអនុញ្ញាតិ)។ ច្បាប់នៃប្រទេសទាំងពីរ ផ្តោតសំខាន់លើវិធានការដាក់ទណ្ឌកម្ម ទៅលើនិយោជក ក្នុងករណីដែលនិយោជកមិនអនុវត្តតាមច្បាប់។

| | ប្រទេសវៀតណាម | ប្រទេសកម្ពុជា |
|---|---|---|
| **តម្រូវការសម្រាប់ពលករបរទេស** | • ប័ណ្ណការងារ<br>• សុខភាពមាំមួន<br>• លក្ខណៈសម្បត្តិគ្រាប់គ្រាន់ និងមានជំនាញការងារ<br>• "នីតិភាពស្របតាមច្បាប់រដ្ឋប្បវេណី[1]"<br>• មិនធ្លាប់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[3, មាត្រា១៦៩] | • និយោជកត្រូវមានលិខិតអនុញ្ញាតការងារជាមុន<br>• សាកសមនឹងការងារ និងមិនមានជំងឺឆ្លង<br>• លិខិតឆ្លងដែនមានសុពលភាព ឆ្លងដែនស្របច្បាប់ និងមានប័ណ្ណស្នាក់នៅត្រឹមត្រូវ [4, មាត្រា២៦១] |
| **តម្រូវការរបស់ក្រុមហ៊ុនដែលជួលកម្មករបរទេស** | • សហគ្រាស អាចជួលជនបរទេសឲ្យធ្វើការងារ "ដែលកម្មករវៀតណាមមិនអាចបំពេញតាមតម្រូវការនៃផលិតកម្ម និងពាណិជ្ជកម្ម"[3, មាត្រា១៧០]<br>• មិនមានកំណត់ចំនួន លើជនបរទេសដែលសហគ្រាសនឹងជួលមកធ្វើការងារ<br>• ក្រុមហ៊ុនត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ដើម្បីជួលកម្មករបរទេស [3, មាត្រា១៧០] ៣០ថ្ងៃមុនពេលជួល[5, មាត្រា៤] | • សហគ្រាសត្រូវ "ផ្តល់អាទិភាពមុនគេដល់ប្រជាជនកម្ពុជា"[4, មាត្រា២៦៣]<br>• មានការកំណត់ភាគរយអតិបរមានៃជនបរទេស ដែលអនុញ្ញាតឲ្យប្រើក្នុងសហគ្រាសនីមួយៗចំនួន១០%[6]នៃបុគ្គលិកសរុប [4, មាត្រា២៦៤] ។ ទោះយ៉ាងណាក៏ដោយ ករណីលើកលែងអាចត្រូវបានធ្វើឡើង ដោយមានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ |
| **ករណីលើកលែង** | មានការលើកលែងចំពោះលិខិតអនុញ្ញាត្តិការងារ សម្រាប់ "សមាជិករួមទុន" ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនភាគហ៊ុន និងប្រធានការិយាល័យតំណាងអង្គការអន្តរជាតិនានា | បុគ្គលដែលគ្រប់គ្រងដោយលក្ខន្តិកៈទូទៅ សម្រាប់មន្ត្រីរាជការស៊ីវិល ឬលក្ខន្តិកៈការទូត ត្រូវបានលើកលែងពីការទទួលបានលិខិតអនុញ្ញាតការងារ[4, មាត្រា១]។ |
| **វិធានការដាក់ទោសទណ្ឌ** | ការធ្វើការដោយគ្មានលិខិតអនុញ្ញាតការងារ នាំទៅដល់ការ | និយោជក ត្រូវជានាថានិយោជិតមានលិខិតអនុញ្ញាតការងារ[7] |

[1] ទស្សនៈដែលដូចជាខ្ចីពីច្បាប់ចិន។ ជាទូទៅ បុគ្គលដែលមានអាយុលើសពី ១៨ឆ្នាំ ប៉ុន្តែបុគ្គលអាយុលើសពី ១៦ឆ្នាំក៏អាចត្រូវបានចាត់ទុកថាមានសមត្ថភាពពេញលេញ ក្នុងករណីដែលពួកគេជាម្ចាស់កម្មសិទ្ធិ [ក្របរដ្ឋប្បវេណី ៣៣/២០០៥ / QH១១ មាត្រា១៩-២០]

| | | |
|---|---|---|
| | និរទេសក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ។ និយោជកអាចត្រូវការផ្អាកប្រតិបត្តិការ រហូតដល់៣ខែ និងពិន័យជាប្រាក់រហូតដល់ ៧៥លានដុង (៣.៣០០ដុល្លារ)[3, មាត្រា ១៧១ ] | ការផ្តន្ទាទោសអាចត្រូវបានពិន័យចំនួន៩០ដង នៃប្រាក់ឈ្នួលប្រចាំថ្ងៃ និងជាប់ពន្ធនាគាររហូតដល់ ៦ឆ្នាំ[4, មាត្រា៣៦៩]។ |

## ៥. ការទទួលបានសញ្ជាតិ

ប្រទេសវៀតណាម មានភាពរឹតត្បឹតខ្លាំងជាងប្រទេសកម្ពុជា ទៅលើការទទួលបានសញ្ជាតិតាមរយៈ *កំណើតតាមរយៈឈាមជ័រ* **jus sanguinis** (ការទទួលបានសញ្ជាតិតាមរយៈឪពុកម្តាយ) និង *ទីកន្លែងកំណើត* **jus solis** (ការទទួលបានសញ្ជាតិតាមរយៈទីកន្លែងកំណើត)។ លក្ខខណ្ឌដែលទទួលបានសញ្ជាតិនៅក្នុងប្រទេសទាំងពីរមានភាពស្រដៀងគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសវៀតណាម មិនតម្រូវឱ្យបង់ថ្លៃសេវា សម្រាប់បុគ្គលដែលមានគុណសម្បត្តិ និង/ឬជនក្រីក្រ ដោយឡែកប្រទេសកម្ពុជា បានលើកលែងលក្ខខណ្ឌមួយចំនួនសម្រាប់ អ្នកដែលបានវិនិយោគ ឬបរិច្ចាគថវិកាក្នុងទំហំទឹកប្រាក់ច្រើន។

ប្រទេសវៀតណាម មានបទប្បញ្ញត្តិពិសេសមួយចំនួន សម្រាប់ក្រុមទទួលរងគ្រោះ ខណៈច្បាប់កម្ពុជាមិនមានបទប្បញ្ញត្តិពិសេសដូចនេះទេ។ បទប្បញ្ញត្តិទាំងនេះពិតជាមានសារៈសំខាន់សម្រាប់ប្រទេសវៀតណាម ដោយសារវៀតណាម មិនមែនជារដ្ឋភាគី នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីភាពគ្មានសញ្ជាតិ (ភាពគ្មានសញ្ជាតិត្រូវបានការពារដោយច្បាប់ជាតិ) និងច្បាប់សញ្ជាតិឆ្នាំ២០០៨ បានបង្កើនមធ្យោបាយជាច្រើនដែលធ្វើឲ្យពលរដ្ឋវៀតណាមងាយនឹងបាត់បង់សិទ្ធិជាពលរដ្ឋ (ពលរដ្ឋវៀតណាម ដែលរស់នៅក្រៅប្រទេស ដែលមិនបានចុះបញ្ជី ជាមួយបេសសកម្មទូតក្នុងរយៈពេលប្រាំឆ្នាំ)[8]។ កម្ពុជាក៏មិនមែនជារដ្ឋភាគី នៃអនុសញ្ញាស្តីពីភាពគ្មានសញ្ជាតិ នឹងផ្ទុយពីវៀតណាម កម្ពុជាមិនមានការពារតាមផ្លូវច្បាប់ណាមួយក្នុងនៅក្នុងក្របខណ្ឌច្បាប់ជាតិរបស់ខ្លួនចំពោះជនដែលគ្មានសញ្ជាតិ។ ទោះជាយ៉ាងណាក៏ដោយ នៅប្រទេសកម្ពុជា ពលរដ្ឋកម្ពុជា មិនងាយនឹងបាត់បង់សញ្ជាតិខ្មែរទេ(តាមច្បាប់) លុះត្រាតែពួកគេបោះបង់សញ្ជាតិដោយស្ម័គ្រចិត្ត[9, មាត្រា១៨]។

| | ប្រទេសវៀតណាម | ប្រទេសកម្ពុជា |
|---|---|---|
| **កំណើត: *ឈាមជ័រ* (*Jus sanguinis*)** | កំណត់ចំពោះកូនដែលមានកំណើត៖<br>• ពីឪពុកម្តាយជាជនជាតិវៀតណាម [10, មាត្រា១៥]<br>• ឪពុក ឬម្តាយណាម្នាក់ជាជនជាតិវៀតណាម ប្រសិនបើ ឪពុក ឬម្តាយណាម្នាក់ដែលគ្មានសញ្ជាតិ(stateless) [10, មាត្រា១៦] | មាននីតិភាពសម្រាប់កូនដែលកើត មានឪពុក ឬម្តាយម្នាក់ជាជនជាតិខ្មែរ ដែលបានរៀបការស្របច្បាប់ ឬ កូននោះទទួលស្គាល់ដោយឪពុកម្តាយ ឬត្រូវបានទទួលស្គាល់ដោយសាលក្រមរបស់តុលាការ ដែលបញ្ជាក់ថាកូននោះបានកើតពីឪពុកម្តាយជាជនជាតិខ្មែរ [9, |

| | | |
|---|---|---|
| | • ឪពុកឬម្ដាយ អាចជ្រើសរើសយកសញ្ញាតិវៀតណាម (សម្រាប់កូន) នៅពេលចុះបញ្ជីកំណើត | មាត្រា៤] |
| **កំណើត: *ទីកន្លែង* *(Jus solis)*** | កំណត់ចំពោះកូនដែលកើតនៅក្នុងប្រទេសវៀតណាម ដោយមិនស្គាល់អត្តសញ្ញាណឪពុកម្ដាយ[10, មាត្រា១៨] ឬឪពុកម្ដាយដែលគ្មានសញ្ញាតិ(stateless) កំពុងរស់នៅក្នុងប្រទេសវៀតណាម [10, មាត្រា១៧] | កំណត់ចំពោះកូនដែលមានឪពុកម្ដាយបរទេស និងរស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ឬចំពោះកូនដែលគ្មានឪពុកម្ដាយ (កូនដែលត្រូវគេបោះបង់ចោល)[9, មាត្រា៤] |
| **លក្ខខណ្ឌសម្រាប់ការទទួលបានសញ្ញាតិ** | • នីតិភាពស្របតាមច្បាប់រដ្ឋប្បវេណី[2]<br>• បានរស់នៅក្នុងប្រទេសវៀតណាមអស់រយៈពេលប្រាំឆ្នាំ<br>• អាចនិយាយភាសាវៀតណាមបានយ៉ាងស្ទាត់ជំនាញ ដើម្បីរស់នៅក្នុងសង្គម<br>• មានសមត្ថភាពក្នុងការប្រកបរបបចិញ្ចឹមជីវិត<br>• គោរពតាមរដ្ឋធម្មនុញ្ញវៀតណាម<br>•មានឈ្មោះវៀតណាម(អាចត្រូវបានជ្រើសរើសដោយអ្នកដាក់ពាក្យ) [10, មាត្រា១៩]<br>ល័ក្ខខ័ណ្ឌទាំងនេះអាចត្រូវបានលើកលែង សម្រាប់អ្នកដែលបានរៀបការ ជាមួយជនវៀតណាម ឬបានរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសវៀតណាម។ ការបង់ថ្លៃដាក់ពាក្យ ក៏អាចត្រូវបានលើកលែងសម្រាប់ជនដែលក្រីក្រ ឬបុគ្គលគ្មានសញ្ញាតិ( stateless )[11, មាត្រា៤] | • វិញ្ញាបនប័ត្រនៃការប្រព្រឹត្តសីលធម៌ល្អ<br>• បានរស់នៅក្នុងប្រទេសកម្ពុជារយៈពេល៧ឆ្នាំ ហើយបច្ចុប្បន្នរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>• ចេះនិយាយភាសាខ្មែរ ចេះសរសេរអក្សរខ្មែរ និងស្គាល់ប្រវត្តិសាស្ត្រខ្មែរ ដើម្បីរស់នៅសមស្របទៅនឹងសង្គមខ្មែរ<br>• មានសម្បទាខាងផ្លូវចិត្ត និងកាយសម្បទាល្អ<br>• មិនដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ<br>ចំពោះជនបរទេសដែលរៀបការជាមួយប្រពន្ធឬប្តីជាជនជាតិខ្មែរ ឬអ្នកដែលមាន"គុណសម្បត្តិពិសេស" ឬបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរស់នៅក្នុងប្រទេសកម្ពុជារយៈពេល៣ឆ្នាំតែប៉ុណ្ណោះជំនួសឱ្យរយៈពេល៧ឆ្នាំ។ ចំពោះអ្នកដែលបានវិនិយោគលើទឹកប្រាក់ជាង១.២៥ពាន់លានរៀល ត្រូវបានលើកលែងចំពោះលក្ខខណ្ឌ |

[2] ទស្សនៈដែលដូចជាខ្ចីពីច្បាប់ចិន។ ជាទូទៅ បុគ្គលមានអាយុលើសពី ១៨ឆ្នាំ ប៉ុន្តែបុគ្គលអាយុលើសពី ១៦ ឆ្នាំក៏អាចត្រូវបានចាត់ទុកថាមានសមត្ថភាពពេញលេញ ក្នុងករណីដែលពួកគេជាម្ចាស់កម្មសិទ្ធិ [ក្រមរដ្ឋប្បវេណី ៣៣/២០០៥ / QH១១ មាត្រា១៩-២០]

| | | |
|---|---|---|
| | | រស់នៅរយៈពេល៧ឆ្នាំ។ អ្នកដែលបានបរិច្ចាគប្រាក់ចំនួនជាង ១ពាន់លានរៀល ត្រូវបានលើកលែងពីគ្រប់លក្ខខណ្ឌទាំងអស់ (ឧទាហរណ៍៖ មិនតម្រូវឲ្យចេះនិយាយខ្មែរ) លើកលែងតែលក្ខខណ្ឌឲ្យរស់នៅក្នុងប្រទេសកម្ពុជា[9]។ |
| **ការស្តារសញ្ជាតិ** | **ការបាត់បង់សញ្ជាតិវៀតណាម អាចត្រូវបានស្តារឡើងវិញក្នុងករណី៖** បុគ្គលនោះបានបោះបង់សញ្ជាតិវៀតណាម ដើម្បីទទួលបានសញ្ជាតិបរទេស ប៉ុន្តែបរាជ័យ ឬក្នុងករណីបុគ្គលនោះ ធ្វើសកម្មភាពវិនិយោគនៅវៀតណាម[10] | ពលរដ្ឋកម្ពុជា មិនអាចបាត់បង់សញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍នោះទេ។ មិនមានបទប្បញ្ញត្តិពិសេស សម្រាប់ការស្តារសញ្ជាតិឡើងវិញនៅក្នុងច្បាប់ ស្តីពីសញ្ជាតិ។ |
| **បទប្បញ្ញត្តិពិសេសសម្រាប់ក្រុមងាយរងគ្រោះ** | មានច្បាប់ពិសេសមួយចំនួន សម្រាប់ក្រុមពិសេស[12]៖<br>• ប្រជាជនដែលមានដើមកំណើតវៀតណាមរស់នៅក្រៅប្រទេស អាចត្រូវបានផ្តល់សញ្ជាតិពីរ ប្រសិនបើពួកគេចង់ទទួលបានសញ្ជាតិវៀតណាម<br>• ជនភៀសខ្លួនដែលរស់នៅក្នុងប្រទេសកម្ពុជា ដែលទទួលរងនូវការធ្វើទុក្ខបុកម្នេញក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អាចទទួលបានសញ្ជាតិវៀតណាម ក្រោមនីតិវិធីសម្របសម្រួលដែលមិនតម្រូវឱ្យបង់ថ្លៃលើពាក្យសុំ បទបញ្ជារជាលាយលក្ខណ៍អក្សរវៀតណាម ឬភស្តុតាងនៃការបដិសេធសញ្ជាតិផ្សេងទៀត។<br>• ស្ត្រីវៀតណាមដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ប៉ុន្តែអាពាហ៍ពិពាហ៍បរាជ័យ ងាយនឹងរងគ្រោះក្លាយជាជនគ្មានសញ្ជាតិ (stateless)។ បញ្ហាជាភាគច្រើនកើតឡើងចំពោះ ការរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិកូរ៉េ និងតៃវ៉ាន់ ដោយសារច្បាប់ | ច្បាប់ស្តីពីសញ្ជាតិកម្ពុជា មិនបានផ្តល់លក្ខខណ្ឌពិសេសសម្រាប់ក្រុមណាមួយឡើយ។ |

| | | |
|---|---|---|
| | នៃប្រទេសទាំងពីរនោះទាមទារឱ្យបោះបង់សញ្ញាតិដើមចោលជាមុនសិន ទើបអនុ- ញ្ញាតឱ្យពលរដ្ឋផ្សេងទទួលបានសញ្ញាតិកូរ៉េ ឬតៃវ៉ាន់។ វិសោធនកម្មច្បាប់ត្រូវបានធ្វើឡើងឲ្យស្របតាមបទដ្ឋាននៃអនុសញ្ញា CEDAW ដើម្បីផ្តល់ឱ្យស្ត្រីរងគ្រោះទទួលបាននូវសញ្ញាតិវៀតណាមក្នុងករណីខាងលើ។ | |

# ឯកសារយោង


1. SOCIALIST REPUBLIC OF VIETNAM (2014). Law Entry, Exit, Transit, and Residence of Foreigners in Vietnam. . 47/2014/*QH*13.
2. ROYAL GOVERNMENT OF CAMBODIA (2016). Sub-Decree on Procedures to Allow Non-Immigrant Foreigners to Enter, Leave, and Reside in the Kingdom of Cambodia. 123 ឯក្រ/ប.ក.
3. SOCIALIST REPUBLIC OF VIETNAM (2012). Labour Code. *Ministry of Labour Invalids and Social Affairs (MoLISA),*.
4. ROYAL GOVERNMENT OF CAMBODIA (1997). Labour Law.
5. SOCIALLIST REPUBLIC OF VIETNAM (2016). Circular: Guidance on Implementation of a Number of Articles of Decree No. 11/2016/ND-CP Dated February 03, 2016 Detailing a Number of Articles of the Labor Code in Respect of Foreign Workers in Vietnam. *Ministry of Labour, War Invalids and Social Affairs, No:* 40/2016/*TT-BLDTBXH.*
6. MINISTRY OF LABOR AND VOCATIONAL TRAINING (2014). Prakas 196 on Employment of Foreign Labour. *Paraks Nº:* 196 ក.ប/ប្រក.
7. MINISTRY OF LABOR AND VOCATIONAL TRAINING (2014). Prakas 195 on Foreigner Work Permit and Foreigner Employment Card. *Prakas No.* 195 ក.ប/ប្រក.
8. NGUYEN, L. (2017). Report on Citizenship Law: Vietnam. *[Global Governance Programme]; GLOBALCIT; Country Reports;* 2017/13.
9. ROYAL GOVERNMENT OF CAMBODIA (1996). Law on Nationality. *available at:* *http://www.refworld.org/docid/*3ae6b5210.*html* *[accessed* 31 *October* 2017].
10. SOCIALIST REPUBLIC OF VIETNAM (2008). Law on Nationality 24/2008/*QH*12.
11. SOCIALIST REPUBLIC OF VIETNAM (2009). Decree No. 78/2009/ND-CP of September 22, 2009, detailing and guiding a number of articles of the Law on Vietnamese Nationality. *No.* 78/2009/*ND-CP, available at:* *http://www.refworld.org/docid/*4b470b2d2.*html* *[accessed* 31 *October* 2017].
12. SOCIALIST REPUBLIC OF VIETNAM (2008). Law on Nationality 24/2008/QH12.